ភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## កិច្ចប្រជុំពិភាក្សាការងារលើវិស័យពន្ធដារ រវាងអគ្គនាយកដ្ឋានពន្ធដារ និង សភាពាណិជ្ជកម្មកម្ពុជានៃយន្តការភាពជាដៃគូអគ្គនាយកដ្ឋានពន្ធដារ-ផ្នែកឯកជន



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង០៩:៣០នាទីព្រឹក ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០១៦ នៅសណ្ឋាគារកាំបូឌីយ៉ាណា មានរៀបចំកិច្ចប្រជុំពិភាក្សា ការងារលើវិស័យពន្ធដារ រវាងអគ្គនាយកដ្ឋានពន្ធដារ និងសភាពាណិជ្ជកម្មកម្ពុជា នៃយន្តការភាពជាដៃគូអគ្គ-នាយកដ្ឋាន ពន្ធដារ-ផ្នែកឯកជន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមគង់វិបុល**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និង**អ្នកឧកញ៉ា គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងជាសហប្រធាននៃយន្តការភាពជាដៃគូនៃយន្តការ ព្រមទាំងមានការចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី សមាជិក សមាជិកា នៃយន្តការភាពជាដៃគូអគ្គ-នាយកដ្ឋានពន្ធដារ និងផ្នែកឯកជន ជាច្រើនរូបទៀត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម គង់ វិបុល និង អ្នកឧកញ៉ា គិត ម៉េង និងជាសហប្រធាននៃយន្តការភាពជាដៃគូ បានសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី សមាជិក សមាជិកា ទាំងអស់ដែលឆ្លៀតពេលដ៏មានតម្លៃ ចូលរួមក្នុងកិច្ចប្រជុំ ដ៏មានអត្ថន័យនាវេលានេះ។

នេះគឺកិច្ចប្រជុំដំបូងបង្អស់ រវាងអគ្គនាយកដ្ឋានពន្ធដារ និងសភាពាណិជ្ជកម្មកម្ពុជា ក្រោយយន្តការនៃភាពជាដៃគូនេះចាប់តាំងពី ក្រសួងសេដ្ឋកិច្ចបានបង្កើត និងដាក់ឲ្យដំណើរការយន្តការ ភាពជាដៃគូអគ្គនាយកដ្ឋានពន្ធដារ-ផ្នែកឯកជនតាមរយៈ

ប្រកាសលេខ ២៩៤ សហវ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១៦។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងអ្នកឧកញ៉ា សហ-ប្រធាន បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះគំនិតផ្តួចផ្តើមបង្កើតឲ្យមានយន្តការភាពជាដៃគូនេះឡើង ក្នុងគោលបំណងបង្កើនកិច្ចសហការខ្ពស់ រវាងអគ្គនាយកដ្ឋានពន្ធដារ និងសភាពាណិជ្ជកម្មកម្ពុជា សំដៅពង្រឹងការអនុវត្តច្បាប់ស្តីពីសារពើពន្ធ ក្នុងគោលដៅសម្រេចឲ្យបាននូវបរិយា-កាសធុរកិច្ចមួយ ប្រកបដោយស្ថិរភាព វិបុលភាព និងការប្រកួតប្រជែងដោយស្មើភាពគ្នា ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីទាំងក្នុងប្រទេសនិងក្នុងតំបន់។

កិច្ចប្រជុំនាព្រឹកនេះ គឺក្នុងបំណងណែនាំនូវសមាសភាពនៃយន្តការ ពីភាគីអគ្គនាយកដ្ឋានពន្ធដារ និងពីភាគីសភាពាណិជ្ជកម្ម និងស្នើសហប្រធាន និងសមាជិកក្រុមការងារជំនាញនីមួយៗនៃយន្តការនេះ ដែលមានសមាសភាពមកពីអគ្គនាយកដ្ឋានពន្ធដារ និងសភាពាណិជ្ជកម្មកម្ពុជា សហការគ្នាបន្តជំរុញអនុវត្តយន្តការនេះ ក្នុងការបង្កើនកិច្ចសហការជជែកពិភាក្សាគ្នា ផ្លាស់ប្តូរបទពិសោធន៍ ចំណេះដឹង និងយោបល់ ដើម្បីស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ ប្រកបដោយសន្តិវិធី និងស្មារតីជាភាគរៈ ចំពោះកិច្ចការប្រឈមទាំងឡាយដែលកើតមានក្នុងពេលអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីពន្ធដារជាពិសេស លើកទឹកចិត្តគ្រប់ធុរជនពីបណ្តាធុរកិច្ចគ្រប់វិស័យទាំងអស់ ព្រមទាំងធ្វើរបាយការណ៍ជាប្រចាំ ជូនសហប្រធាននៃយន្តការ។

លើសពីនេះទៅទៀត ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងអ្នកឧកញ៉ា សហប្រធានយន្តការភាពជាដៃគូ ស្នើក្រុមការងារជំនាញទាំងអស់ របស់យន្តការភាពជាដៃគូ ផ្តោតការយកចិត្តទុកដាក់ ជំរុញការកែលម្អបន្ថែមការពិគ្រោះយោបល់ផ្នែកនីតិវិធីពន្ធដារ ការខិតខំរិះរកវិធានការសម្របសម្រួល ដើម្បីអនុវត្តដោយរលូននូវនីតិវិធីនេះ សំដៅធ្វើឲ្យមានសុខដុមនីយកម្មភាពជាដៃគូរវាងអគ្គនាយកដ្ឋានពន្ធដារនិងវិស័យឯកជន និងលើកកម្ពស់កាតព្វកិច្ច និងវប្បធម៌សារពើពន្ធ ក្នុងគោលដៅ ប្រមូលចំណូលពន្ធប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់។



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ